**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៨-១០-២០២១-អ.វ.ត.ក/អ.ជ.ត.ក (០៥)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០២១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 01-Nov-21, 10:13
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តបទៅនឹងសំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣**

---

**ដាក់ដោយ** ÷

**សហមេធាវី** ៖

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន** ÷

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល** ៖

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម C. N. JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងរឿងក្ដី ០០៣**

ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់ ស.ព.អ. បតទៅនឹង

សំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្ដី”) តាមរយៈនេះ ឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ.”) តបទៅនឹងសំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣។ ស.ព.អ. លើកឡើងនូវទឡ្ហីករណ៍ដដែលៗ ដែលមិនបានទទួលជោគជ័យនៅចំពោះមុខអង្គបុរេជំនុំជម្រះ (“អ.ប.ជ.”) និង អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក.”) ដោយថ្លែងខុសឆ្គងពីច្បាប់ដែលអាចអនុវត្តបាន ដោយថ្លែងខុសឆ្គងពីការយល់ឃើញរបស់ អ.ប.ជ. និង អ.ជ.ត.ក. ដោយបង្ហាញខុសឆ្គងពីទឡ្ហីករណ៍របស់មេធាវីការពារក្ដី និង លើកឡើងនូវទឡ្ហីករណ៍ដែលមិនពាក់ព័ន្ធ។ មិនមានការបង្ហាញនូវសំអាងហេតុសមហេតុផលណាមួយ ដែលធ្វើឱ្យ អ.ជ.ត.ក. ងាកចេញពីសេចក្ដីសម្រេចរបស់ពួកគាត់នៅក្នុងរឿងក្ដី ០០៤/២ ឬ មិនមានកំហុសណាមួយនៅក្នុងសំអាងហេតុ ឬ ការផ្លាស់ប្ដូរណាមួយនៅក្នុងកាលៈទេសៈទាំងឡាយ ដែលធ្វើឱ្យត្រឹមត្រូវតាមផ្លូវច្បាប់ឱ្យ អ.ជ.ត.ក. សម្រេចរឿងក្ដី ០០៣ ខុសគ្នានោះទេ។ ជាសរុប ទឡ្ហីករណ៍របស់ ស.ព.អ គួរត្រូវច្រានចោល។

១. ស.ព.អ. អះអាងដោយភាន់ច្រឡំថា គោលការណ៍នៃការប្រព្រឹត្តដោយស្មើភាព មិនបានអនុវត្តនៅក្នុងករណីនេះបានទេ ដោយសារថាសេចក្ដីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្ដី ០០៤/២ បានពឹងផ្អែកទៅលើកំហុសអង្គច្បាប់ ដែល“ទាញចេញពីសេចក្ដីសម្រេចដែលមិនត្រឹមត្រូវរបស់ អ.ប.ជ. ថា ការចេញដីកាដំណោះស្រាយគឺខុសច្បាប់”[1]។ ទឡ្ហីករណ៍ទាំងនេះត្រូវបានលើកឡើង និង ត្រូវបានច្រានចោលហើយ[2]។ ដោយសារមានសិទ្ធិអំណាច “លើកបញ្ហាឡើង*តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន*” ប្រសិនបើ អ.ជ.ត.ក. មិនយល់ស្របជាមួយនឹងសេចក្ដីសម្រេចរបស់ អ.ប.ជ. អង្គជំនុំជម្រះគួរត្រូវកែតម្រូវកំហុសនោះ”[3]។

២. ស.ព.អ. អះអាងដោយភាន់ច្រឡំថា ទឡ្ហីករណ៍របស់មេធាវីការពារក្ដីអំពីការប្រព្រឹត្តដោយស្មើភាពថ្លែងខុសពីអង្គច្បាប់ ដោយសារថាគោលការណ៍នេះ “គ្រាន់តែតម្រូវឱ្យធានាថា ចុងចោទនៅ

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០២១ ឯកសារ 4/1 (“ចម្លើយរបស់ ស.ព.អ.”) កថាខណ្ឌ ១, កថាខណ្ឌ ១១-១៣។

[2] ចម្លើយរបស់ មាស មុត តបទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះ មិនបានបញ្ជូនរឿងក្ដី ០០៣ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្ត អ.វ.ត.ក. ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០២១ ឯកសារ 3/1 កថាខណ្ឌ ១-៥។

[3] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៥, ១៦។

ក្នុងរឿងក្ដីស្រដៀងគ្នា ត្រូវដោះស្រាយក្នុងវេទិកាស្រដៀងគ្នា ដោយមាននីតិវិធីស្រដៀងគ្នា”[4]។ គឺមិនសមហេតុផលទេ។ វិធាន ២១ នៃវិធានផ្ទៃក្នុង “តម្រូវយ៉ាងច្បាស់ថា ស្ថាប័នតុលាការនៅ អ.វ.ត.ក. ត្រូវធានានូវសុចរិកភាពផ្លូវច្បាប់ និង ចែងថា “បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា [...] ត្រូវយក *វិធានដូចគ្នា*មកអនុវត្ត”[5]។ “បញ្ញត្តិត្រឹមត្រូវនៃវិធាន ២១ នៃវិធានផ្ទៃក្នុង” តម្រូវថា ជាប្រយោជន៍សុចរិតភាពផ្លូវច្បាប់ និង សមភាពចំពោះមុខច្បាប់ អង្គជំនុំជម្រះ អ.វ.ត.ក. គួរត្រូវងាកចេញពីសេចក្ដីសម្រេចពីមុន សម្រាប់តែ“សំអាងហេតុសមហេតុផលនៃប្រយោជន៍យុត្តិធម៌ប៉ុណ្ណោះ”[6]។

៣. ស.ព.អ. អះអាងដោយភាន់ច្រឡំថា ពុំមានសំអាងហេតុសមហេតុផលណាមួយ ក្នុងការងាកចេញពីសេចក្ដីសម្រេចរបស់ អ.ជ.ត.ក. នៅក្នុងរឿងក្ដី ០០៤/២ ឡើយ ដោយសារថាដីកាដំណោះស្រាយគឺមិនត្រូវបានចេញដោយខុសច្បាប់ និង ដោយសន្មតថា សម្រាប់គោលបំណងវែកញែក ការចេញក្នុងពេលដំណាលគ្នាគឺខុសច្បាប់ ដីកាទាំងនេះមិនត្រូវចាត់ទុកជាមោឃៈ និង ឥតបានការទេ ហើយរឿងក្ដីត្រូវបញ្ជូនបន្តទៅជំនុំជម្រះដោយផ្អែកតាមគោលជំហរដើម[7]។ ដូចដែលបានពន្យល់នៅក្នុងចម្លើយរបស់ មាស មុត តទៅនឹងបណ្ដឹងសាទុក្ខរបស់ ស.ព.អ. អំពីការខកខានរបស់អង្គបុរេជំនុំជម្រះ មិនបានបញ្ជូនរឿងក្ដី ០០៣ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្តិ អ.វ.ត.ក.[8] និង បានលើកទឡ្ហីករណ៍ខាងក្រោមក្នុងកថាខណ្ឌ ៤-៧ ស.ព.អ. មិនបានបង្ហាញ

---

[4] ចម្លើយរបស់ ស.ព.អ. កថាខណ្ឌ ៩-១០។

[5] សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការសម្រេចស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ឈ្មោះ ជុំ នៅ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D11/3/4/2 មតិយោបល់របស់ចៅក្រម Chung និង Downing កថាខណ្ឌ ១៦ (ការគូសបញ្ជាក់បន្ថែម)។

[6] *សូមមើល រឿងក្ដី នួនជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ. សេចក្ដីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១១ ឯកសារ E100/6 កថាខណ្ឌ ២៦។ *សូមមើលផងដែរ* សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការសម្រេចស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ឈ្មោះ ជុំ នៅ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D11/3/4/2 មតិយោបល់របស់ចៅក្រម Chung និង Downing កថាខណ្ឌ ១៦-១៧។ *រឿងក្ដី រដ្ឋអាជ្ញា តទល់ Semanza* សំណុំរឿងលេខ ICTR-97-20-A សេចក្ដីសម្រេច ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០០ កថាខណ្ឌ ៩២។

[7] ចម្លើយរបស់ ស.ព.អ. កថាខណ្ឌ ១៥-៣២។

[8] ចម្លើយរបស់ មាស មុត តបទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះ មិនបានបញ្ជូនរឿងក្ដី ០០៣ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្ត អ.វ.ត.ក. ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០២១ ឯកសារ 3/1 (“ចម្លើយរបស់ មាស មុត”) កថាខណ្ឌ ១-១៧។

សំអាងហេតុសមហេតុផលណាមួយ ក្នុងការងាកចេញពីសេចក្តីសម្រេចរបស់ អ.ជ.ត.ក. នៅក្នុងរឿងក្តី ០០៤/២ កំហុសនៅក្នុងសំអាងហេតុ ឬ ការផ្លាស់ប្តូរក្នុងកាលៈទេសៈទាំងឡាយ ដែលនឹងធ្វើឱ្យត្រឹមត្រូវតាមច្បាប់ឱ្យ អ.ជ.ត.ក. សម្រេចរឿងក្តី ០០៣ ខុសគ្នានោះទេ។

៤. ស.ព.អ. អះអាងដោយភាន់ច្រឡំថា មេធាវីការពារក្តីប្រកាន់យកគោលជំហរដោយមិនផ្លាស់ប្តូរថា ដីកាដំណោះស្រាយទាំងពីរត្រូវបានអនុញ្ញាត[9]។ យ៉ាងសមគួរ ស.ព.អ. ភ្លេចបញ្ចូលការអះអាងបានធ្វើឡើងនៅក្នុងអំឡុងពេលទឡ្ហីករណ៍ផ្ទាល់មាត់នៅចំពោះមុខ អ.ប.ជ. មេធាវីការពារក្តីបានស្នើអនុញ្ញាតយ៉ាងច្បាស់ពីលទ្ធភាពដែលថា ទាំង ស.ព.អ. និង មេធាវីការពារក្តីអាចមានកំហុសនៅក្នុងទឡ្ហីករណ៍ក្នុងបណ្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សររបស់ខ្លួន ដែលថា ក្របខណ្ឌ អ.ជ.ត.ក. អនុញ្ញាតឱ្យ ស.ច.ស. ចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា ហើយថាប្រសិនបើ អ.ប.ជ. បានសម្រេចផ្សេងពីនេះ (ដូចដែលពួកគាត់បានសម្រេច) នោះ អ.ប.ជ. គួរត្រូវបញ្ជូនសំណុំរឿង ០០៣ ត្រឡប់ទៅ ស.ច.ស. ដោយមានសេចក្តីបង្គាប់ឱ្យចេញដីកាដំណោះស្រាយតែមួយ ឬ ក៏ពិនិត្យសំណុំរឿង ០០៣ ដោយខ្លួនឯង ហើយចេញដីកាដំណោះស្រាយផ្ទាល់ខ្លួន[10]។ ដោយសារតែសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ មេធាវីការពារក្តីទទួលប្រកាន់យកដោយមិនផ្លាស់ប្តូរថា ដីកាដំណោះស្រាយទាំងពីរគឺខុសច្បាប់[11]។

---

[9] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្ត អ.វ.ត.ក. ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០២១ ឯកសារ 3 កថាខណ្ឌ ១៦។

[10] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/18.2 ម៉ោង ១២.០១.៣៤-១២.០៤.១៤។ *សូមមើលផងដែរ* សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២ ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២០ ឯកសារ D267/24 កថាខណ្ឌ ១៥។ សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០២០ ឯកសារ D267/27 កថាខណ្ឌ ២៤។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក សំណើរបស់ មាស មុត សុំធ្វើអន្តរាគមន៍ និង ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2/2 កថាខណ្ឌ ១១-១២។

[11] សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២ ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២០ ឯកសារ D267/24 កថាខណ្ឌ ១៥-៣៩។ សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះ

៥. ស.ព.អ. អះអាងដោយភាន់ច្រឡំថា ការចេញដីកាដំណោះស្រាយទាំងពីររបស់ ស.ច.ស. គឺមិនមែនជាកំហុសនីតិវិធីស្លាប់រស់នោះទេ[12]។ ការពឹងផ្អែកដោយមិនសមហេតុផលទៅលើបទដ្ឋាននៃបណ្តឹងសាទុក្ខចំពោះវិការៈនីតិវិធីនៅក្នុងសាលដីកាមួយ ស.ព.អ. មិនបានអើពើនឹងការយល់ឃើញជាឯកច្ឆន្ទរបស់ អ.ប.ជ. ដែលថាកំហុស "ធ្ងន់ធ្ងរ" និង "យ៉ាងច្បាស់ក្រឡែក" របស់ ស.ច.ស. គឺ "ច្រើនជាងការរំលោភបំពានទៅលើគោលការណ៍ជាមូលដ្ឋាននៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក." ដោយសារពួកគាត់ "បានបង្កផលប៉ះពាល់ដល់ប្រព័ន្ធទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ"[13]។ ភាសា និង សម្តីដាច់ម៉ាត់របស់ អ.ប.ជ. ដែលគ្មានលក្ខណៈពិសេស នៅក្នុងការបញ្ជាក់បង្ហាញពីមតិយោបល់របស់ពួកគាត់ ទៅលើកំហុសរបស់ ស.ច.ស. ក្នុងការចេញដីកាដំណោះស្រាយពីរ អាចនាំឱ្យមិនការបញ្ចប់ផ្សេងទៀតទេ។ ហើយការយល់ឃើញណាមួយដែលចៅក្រមជាតិ និង អន្តរជាតិ នៃ អ.ប.ជ. អាចយល់ដឹងពីទឡ្ហីករណ៍នៃការធ្វើឱ្យត្រឹមត្រូវតាមផ្លូវច្បាប់របស់ពួកគាត់ ចំពោះការគាំទ្ររបស់ពួកគាត់ទៅលើដីកាដំណោះស្រាយនីមួយៗ ត្រូវបានច្រានចោលយ៉ាងច្បាស់ក្រលែកដោយ អ.ជ.ត.ក.[14]។

៦. ស.ព.អ. អះអាងដោយភាន់ច្រឡំថា អ.ប.ជ. បានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង ថា មតិយោបល់របស់ចៅក្រមជាតិនៃ អ.ប.ជ. "គ្រាន់តែឆ្លុះបញ្ចាំងពីការបដិសេធរបស់ចៅក្រមជាតិនៃ អ.ប.ជ. ក្នុងការបំពេញកិច្ចចំពោះសេចក្តីសម្រេចរបស់ខ្លួនផ្ទាល់ និង នៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[15]។ ប្រសិនបើ ដូចដែល ស.ព.អ. បានអះអាង អ.ប.ជ. បាន"យល់

ថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០២០ ឯកសារ D267/27 កថាខណ្ឌ ២៦-៣២។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក សំណើរបស់ មាស មុត សុំធ្វើអន្តរាគមន៍ និង ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2/2 កថាខណ្ឌ ១០-១៣។ ចម្លើយរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២១ ឯកសារ D270/4 កថាខណ្ឌ ១៩-២១, កថាខណ្ឌ ២៣-២៤។ សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D272 កថាខណ្ឌ ១៥(ឃ)។ សំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣ ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០២១ ឯកសារលេខ 4 កថាខណ្ឌ ៥៧-៦១។

[12] ចម្លើយរបស់ ស.ព.អ. កថាខណ្ឌ ២២-២៦។

[13] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១ ឯកសារ D266/27 & D267/35 កថាខណ្ឌ ៨៨, ១០៥, ១០៨។ ចម្លើយរបស់ មាស មុត កថាខណ្ឌ ៩។

[14] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៥២-៥៣, កថាខណ្ឌ ៦១។

[15] ចម្លើយរបស់ ស.ព.អ. កថាខណ្ឌ ២៧-២៩។

ដឹងជាទូទៅថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺមានសុពលភាព" នោះអង្គជំនុំជម្រះមិនគួរត្រូវប្រកាសជាបន្តបន្ទាប់ថា "ពុំមានអត្ថបទច្បាប់ដែលតម្រូវឱ្យអង្គបុរេជំនុំជម្រះ ឈានទៅដល់សេចក្តីសម្រេចជាឯកច្ឆន្ទ" និង ថា អង្គជំនុំជម្រះ "មិនអាចសម្រេចទៅលើចំណុចដែលលើកឡើងនៅក្នុងសំណើនៅក្នុងផ្នែកសម្រេចសេចក្តីលើសេចក្តីពិចារណារបស់ខ្លួនក្នុងរឿងក្តី ០០៣"[16]។ ទទ្បីករណ៍ទាំងឡាយដែលចៅក្រមទាំងប្រាំនាក់ បានសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ... នោះត្រូវចាត់ទុកជាបានការ ដោយយោងតាមពាក្យពេចន៍ផ្ទាល់របស់ អ.ប.ជ." [17]។

៧. ស.ព.អ. អះអាងដោយភាន់ច្រឡំថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែបញ្ជូនបន្តទៅជំនុំជ្រះ ផ្អែកតាមគោលជំហរដើម ដោយសារដីកានេះមិនត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ.[18]។ ជាថ្មីម្តងទៀត ស.ព.អ. មិនអើពើនឹងការយល់ឃើញរបស់ អ.ជ.ត.ក. ដែលថា "ទទ្បីករណ៍ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ... ថា ក្នុងករណីពុំមានកិច្ចព្រមព្រៀង និង សំឡេងភាគច្រើនលើសលុបគាំទ្រដីកាសម្រេចលើកលែងចោទប្រកាន់ *គោលជំហរដើម* ត្រូវចាត់ទុកជាបានការ។ ... គេសវេស ឬ មិនអើពើពីផលវិបាកនៃការយល់ឃើញ*ជាឯកច្ឆន្ទ* របស់អង្គបុរេជំនុំជម្រះ ដែលថា ដីកាដំណោះស្រាយគឺជាលទ្ធផលនៃចំណាត់ការ*ខុសច្បាប់ និង ពុំត្រឹមត្រូវតាមច្បាប់*" [19]។

៨. ស.ព.អ. អះអាងដោយភាន់ច្រឡំថា ពុំមានការពន្យារពេលដោយសមហេតុផលនៅក្នុងរឿងក្តី ០០៣ ដោយការបញ្ចូលខុសឆ្គងថា "ពេលវេលាពាក់ព័ន្ធដែលចាប់ផ្តើមគិតចាប់ពីពេលដែល [លោក មាស មុត] ត្រូវបាន"ជូនដំណឹង*ជាផ្លូវការ*ថា ខ្លួននឹងត្រូវរងការចោទប្រកាន់"" នៅ "ថ្ងៃទី ២៨ ខែ

---

[16] សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង សហមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០២១ ឯកសារ D275/1 & D272/3 កថាខណ្ឌ ៦៨, ៧៧។

[17] ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ ដើម្បីបញ្ចប់សំណុំរឿង ០០៣ ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០២១ ឯកសារ D273 កថាខណ្ឌ ២។

[18] ចម្លើយរបស់ ស.ព.អ. កថាខណ្ឌ ៣០-៣២។

[19] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ ៦៧ (អក្សរទ្រេតនៅក្នុងសំណៅដើម)។

វិច្ឆិកា ឆ្នាំ ២០១៨ គឺប្រហែលបីឆ្នាំមុន"[20] ដែលកត់សម្គាល់ *ការផ្លាស់ប្តូរទាំងស្រុង* ពីទឡ្ហីករណ៍របស់គាត់នៅចំពោះមុខ អ.ប.ជ. ដែលថា "ពេលវេលាពាក់ព័ន្ធគឺទើបតែ (៩) ឆ្នាំ ..."[21]។ មិនតែប៉ុណ្ណោះ ការគណនាជាក់លាក់នៃពេលវេលាគឺមិននៅទីនេះ ឬ ទីនោះទេ។ ប្រសិនបើពិចារណាថា "បន្ទាប់ពីរយៈពេលដប់បីឆ្នាំ ពុំមានទឡ្ហីករណ៍ណាមួយដែលថា អោ អាន ស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក នោះទេ" អ.ជ.ត.ក. បានយល់ឃើញថា "ក្នុងករណីពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាក់លាក់ និង អាចអនុវត្តបាន ប្រឆាំងនឹង អោ អាន រឿងក្តី ០០៤/២ ប្រឆាំងនឹងរូបគាត់ គប្បីត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក."[22]។ ស.ព.អ. ពុំបានបង្ហាញសំអាងហេតុសមហេតុផលណាមួយ សម្រាប់ការងាកចេញពីសំអាងហេតុរបស់ អ.ជ.ត.ក. នៅក្នុងរឿងក្តី ០០៤/២ ទេ[23]។

៩. ស.ព.អ. អះអាងដោយភាន់ច្រឡំថា គោលជំហររបស់ ស.ច.ស. ដែលរឿងក្តី ០០៣ ដល់ពេលត្រូវបញ្ចប់ គឺ"មិនពាក់ព័ន្ធ ជាកំហុស និង បដិកូល"[24]។ មតិយោបល់របស់ ស.ច.ស. គឺពាក់ព័ន្ធដោយសារថាពួកគាត់បានពន្យល់ពី៖ (ក) ព្រឹត្តិការណ៍ដែលនាំឱ្យចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និង ផ្ទុយគ្នា (ខ) ការយល់ដឹងរបស់ពួកគាត់ពីភាពត្រឹមត្រូវ និង ផលប៉ះពាល់នៃសេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ (គ) ឧបាស្រ័យដែលមានចំពោះមុខ អ.ប.ជ នៅក្នុងការដោះស្រាយភាពទាល់ច្រក *ផ្អែកទៅលើ*សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ (ដែល អ.ប.ជ. មិនបានអើពើ) និង (ឃ) របៀបដែល អ.ប.ជ. បោះបង់ចោលទំនួលខុសត្រូវរបស់ខ្លួនសម្រាប់ដំណោះស្រាយដែលសមស្របនៃរឿងក្តី បានផ្តល់"ផលវិបាកធ្ងន់ធ្ងរ" ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក មាស មុត និង ទទួលបានការសម្រេចជា

[20] ចម្លើយរបស់ ស.ព.អ. កថាខណ្ឌ ៣៦។

[21] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ មាស មុត សុំឱ្យបញ្ចប់នីតិវិធី បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០២១ ឯកសារ D272/1 កថាខណ្ឌ ៦។

[22] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ ៦៩។

[23] *សូមមើល ខាងលើ*ជើងទំព័រ ៦។

[24] ចម្លើយរបស់ ស.ព.អ. កថាខណ្ឌ ៤៧-៥០។

ស្ពាពរ និង ឆាប់រហ័សក្នុងរឿងក្តីរបស់គាត់[25]។

១០. ស.ព.អ. អះអាងដោយភាន់ច្រឡំថា "ទឡ្ហីករណ៍បន្ថែមរបស់មេធាវីការពារក្តីគឺមិនពាក់ព័ន្ធ និង/ឬ មានកំហុស" ដោយយោងលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ស.ច.ស. និង អ.ប.ជ. "ដោយលើកទឡ្ហីករណ៍ថា ចៅក្រមបម្រុង Kasper-Ansermet មិនដែលបានស្បថចូលកាន់តំណែលជា ស.ច.ស" និង ដោយធ្វើ"ការអះអាងដោយគ្មាមូលដ្ឋានថា វិបត្តិចវិកា "គម្រាមកំហែងដល់សុចរិតភាពនៃដំណើរការនីតិវិធី អ.វ.ត.ក.""[26]។ ឯកសារយោងដែលមេធាវីការពារក្តីបានលើកឡើងក្នុងកាលប្បវត្តិ ទៅនឹងសំណើរបស់គាត់សុំបញ្ចប់សំណុំរឿង ០០៣ គឺសម្រាប់បរិបទ៖ បន្ទាប់ពីរយៈពេល ១៣ ឆ្នាំ ពុំមានការព្រមព្រៀងណាមួយទៅលើបញ្ហាដែលថា តើលោក មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែរឬយ៉ាងណា។ ជាសរុប អ.ជ.ត.ក. គួរត្រូវច្រានចោលទឡ្ហីករណ៍របស់ ស.ព.អ. ដែល"មិនពាក់ព័ន្ធយ៉ាងច្បាស់"[27]។

អាស្រ័យហេតុនេះ សម្រាប់ហេតុផលដែលបានជម្រាបជូនខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលគួរ **បដិសេធ** ចម្លើយរបស់ ស.ព.អ. **អនុញ្ញាត** តាមសំណើរបស់លោក មាស មុត សុំបញ្ចប់រឿងក្តី ០០៣ និង **បញ្ចប់** ស.ច.ស. បោះត្រា និង បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណាសារ។

សូមលោកចៅក្រមទទួលយកសេចក្តីគោរពអំពីយើងខ្ញុំ។

---

[25] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែសភា ឆ្នាំ ២០២១ ឯកសារ, D270/7 កថាខណ្ឌ ១៥-៣៧, កថាខណ្ឌ ៤០-៤៣។

[26] ចម្លើយរបស់ ស.ព.អ. កថាខណ្ឌ ៥២-៥៤។

[27] ទឡ្ហីករណ៍ដែលពុំមានសក្តានុពលធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធ ឬ កែប្រែសេចក្តីសម្រេចដែលរងការជំទាស់តវ៉ាបានទេនោះ អង្គជំនុំជម្រះតុលាការកំពូលអាចបដិសេធទឡ្ហីករណ៍នេះចោលភ្លាមៗ ហើយមិនចាំបាច់ធ្វើការពិចារណាទៅលើអង្គសេចក្តី។ ទឡ្ហីករណ៍បែបនេះរួមបញ្ចូលទាំងទឡ្ហីករណ៍ "ដែលមិនពាក់ព័ន្ធយ៉ាងច្បាស់"។ *សូមមើល រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ២០។ *រឿងក្តី រដ្ឋអាជ្ញា តទល់ Stanišić and Simatović* សំណុំរឿងលេខ IT-03-69-A សាលក្រម ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១** ខែ**វិច្ឆិកា** ឆ្នាំ **២០២១**

**សហមេធាវីការពារក្ដីលោក មាស មុត**

| | |
|---|---|
| _____________________ | _____________________ |
| អាង ឧត្ដម | Michael G. KARNAVA |